ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

លេខ ១៣២៥ ព.ណ.ន.ជពកព

ថ្ងៃអង្គារ ៥កើត ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០២៦

# សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់លោក-លោកស្រី ដែលជាពាណិជ្ជករ និងសាធារណជនទូទៅឱ្យបានជ្រាបថា ស្ថានបេសកកម្មឥណ្ឌាប្រចាំអាស៊ាន នឹងរៀបចំ «កម្មវិធីតាំងពិព័រណ៍អាស៊ាន-ឥណ្ឌា ឆ្នាំ២០២៦ (ASEAN-India Bazaar 2026)» ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៦ នៅសណ្ឋាគារ The Westin ទីក្រុងហ្សាការតា ប្រទេសឥណ្ឌូនេស៊ី។ កម្មវិធីនេះរៀបចំឡើងក្នុងគោលបំណងបង្ហាញពីវប្បធម៌ និងប្រពៃណីរបស់អាស៊ាន និងឥណ្ឌា តាមរយៈសិប្បកម្ម សម្លៀកបំពាក់ ម្ហូបអាហារ និងផ្តល់ជាកាលានុវត្តភាពសម្រាប់សហគ្រាសធុនមីក្រូ តូច និងមធ្យម (MSMEs) នៃបណ្តាប្រទេសសមាជិកអាស៊ាន និងឥណ្ឌា ក្នុងការតាំងបង្ហាញ និងផ្សព្វផ្សាយផលិតផល ឬសេវាកម្មរបស់ខ្លួនរួមគ្នា។ គណៈកម្មការរៀបចំ បានផ្តល់ស្តង់ចំនួនមួយជូនក្រុមហ៊ុនកម្ពុជា ដែលកំពុងធ្វើប្រតិបត្តិការធុរកិច្ចក្នុងវិស័យខាងលើ ដើម្បីចូលរួមក្នុងកម្មវិធីនេះ។

ក្រសួងពាណិជ្ជកម្ម ក្នុងនាមអ្នកសម្របសម្រួល សូមអញ្ជើញ លោក-លោកស្រី ដែលជាពាណិជ្ជករ និងសាធារណជនទូទៅដែលមានចំណាប់អារម្មណ៍ចង់ចូលរួមក្នុងព្រឹត្តិការណ៍ខាងលើ សូមធ្វើការទំនាក់ទំនងមកនាយកដ្ឋានជំរុញពាណិជ្ជកម្ម និងកិច្ចការពិព័រណ៍ នៃអគ្គនាយកដ្ឋានគោលនយោបាយ និងជំរុញពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម តាមរយៈអាសយដ្ឋាន៖ ដីឡូត៍លេខ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ទូរស័ព្ទលេខ៖ +៨៥៥ ៧៧ ៣៦១ ៨៣៦ / +៨៥៥ ៨៧ ៧៥៥ ៥៥១ ឬ តាមរយៈប្រព័ន្ធទូរស័ព្ទសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម ១២៦៦ ឬអ៊ីម៉ែល៖ oun.veasna@moc.gov.kh / tong.rita@moc.gov.kh៕

ស្រមាប់ចុះឈ្មោះ

GO.gov.KH

សូមអរគុណ!